## មេរៀនទី១ សារៈប្រយោជន៍ និង លក្ខណៈសម្បត្តិនៃការចិញ្ចឹមមាន់

### ១.សារៈប្រយោជន៍នៃការចិញ្ចឹមមាន់

**ការចិញ្ចឹមមាន់ពូជក្នុងស្រុកមានសារៈប្រយោជន៍សំខាន់ដូចជាៈ**

-ងាយបន្សាំទៅនឹងអាកាសធាតុស្រុកស្រែចំការជនបទយើង ហើយមានការលូតលាស់ឆាប់រហ័ស ។

-សាច់ និងស៊ុតប្រើប្រាស់ជាចំណីអាហារក្នុងគ្រួសារ

-ទុកពូជបានសំរាប់ចិញ្ចឹមបន្ត

-ផ្តល់លាមកជាជីសំរាប់ការដាំដុះដំណាំផ្សេងៗ

-អាចម៍មាន់អាចប្រើជាចំណីសត្វ ដើម្បីយកកាល់ស្យូម និងផូស្វ័រ ទៅចិញ្ចឹមសត្វដទៃទៀត

-បង្កើនប្រាក់ចំណូលគ្រួសាររបស់ប្រជាកសិករ

### ២.លក្ខណៈសម្បត្តិនៃការចិញ្ចឹម

-អាចចិញ្ចឹមលែងអោយស៊ីអាហារដែលមានស្រាប់ក្នុងបរិវេណភូមិដ្ឋាន ដោយមិនខាតបង់ពេលវេលាក្នុង ការថែរក្សា និងចំណាយទុនយ៉ាងច្រើននោះទេ ។

-អាចក្រាបពងនិងចិញ្ចឹមកូនដោយខ្លួនឯង

-ក្នុង១ឆ្នាំមេមាន់អាចផ្តល់ស៊ុតយ៉ាងតិច ៣-៤ ដងក្នុងមួយឆ្នាំ និងញាស់ម្តងៗបានកូន ៨-១០ក្បាល

-រស់ជាតិ ឆ្ងាញ់ពិសារ សាច់ណែន ខ្លាញ់តិច

-អាចចិញ្ចឹមជាអាជីពបាន ព្រោះលក់បានតំលៃខ្ពស់ហើយថេរមានទីផ្សារល្អ

-ផ្តល់ស៊ុតមានរស់ជាតិឆ្ងាញ់ ហើយថ្លៃជាងស៊ុតទា

### *៣.ការចិញ្ចឹមមាន់សាច់ជាទំលាប់កន្លងមក*

-កសិករនៅគ្រប់ទីកន្លែងទាំងអស់នៃប្រទេសកម្ពុជា មិនសូវចាប់អារម្មណ៍លើធនធានចំណីអាហារដែល មាន ឬត្រូវដាំបន្ថែមឱ្យស្របទៅតាមល័ក្ខខ័ណ្ឌជាក់លាក់របស់ភូមិសាស្ត្រតំបន់នីមួយៗឡើយ ។

-ការចិញ្ចឹមមាន់សាច់កសិករចិញ្ចឹមដោយមិនគិតពីទ្រុង ឬក៏ទំហំផ្ទៃដីសំរាប់វារស់នៅ ។ ការដេករបស់ មាន់គឺកសិករគ្រាន់តែធ្វើបង្គងបន្តិចបន្តួច ឬក៏តាមកន្លែងដែលវាអាចដេកបានដោយខ្លួនវា ។

-ចំពោះការផ្តល់ចំណី , ទឹក ,សំអាតទ្រុង កសិករមិនសូវចំណាយពេលសំរាប់គិតគូរដល់វាឡើយ ។

-ការចិញ្ចឹមមាន់កសិករមិនមានការចាប់អារម្មណ៍ចំពោះតំលៃ និងការសំរួលដល់ចំណូលក្នុងគ្រួសារទេគឺ គាត់ចិញ្ចឹមសំរាប់តែហូបបន្តិចបន្តួចប៉ុណ្ណោះ ។

### ៤.គំរោងឈានទៅរកការចិញ្ចឹម

-ប្រជុំពិភាក្សាជាមួយអ្នកដែលមានបទពិសោធន៍ចិញ្ចឹមមាន់ និងអ្នកដែលមានចំណូលចិត្តនៅក្នុងមូលដ្ឋានរបស់អ្នកផង ។

-ពិភាក្សាសួរយោបល់ពេទ្យសត្វភូមិ ស្តីពីបច្ចេកទេសចិញ្ចឹម , ថ្នាំសង្កូវ , វ៉ាក់សាំងផ្សេងៗ ដែលត្រូវការ និង សួរគ្រូបច្ចេកទេសកសិកម្មខេត្តពីការវិភាគសេដ្ឋកិច្ច លើការចិញ្ចឹមមាន់ ១០ក្បាល ឡើងទៅ

-រៀបចំគំរោងការមួយអោយបានច្បាស់លាស់ ហើយប្រើគំរោងការនេះជា ឧទាហរណ៍ដឹកនាំការចិញ្ចឹមមាន់របស់អ្នក ។



## មេរៀនទី២ ការចិញ្ចឹមមាន់

### សេចក្តីផ្តើម

មាន់ជាសត្វស្លាបមួយប្រភេទដែលកសិករយើងនិយមចិញ្ចឹម ព្រោះវាផ្តល់ ស៊ុត សាច់ ជាអាហារ និងអាចផ្តល់ប្រាក់ចំណូលសំរាប់ជួយកែលំអសេដ្ឋកិច្ចគ្រួសារប្រជាកសិករយើងនៅតាមជនបទទៀតផង។ ប្រជាកសិករដែលមានពេលទំនេរ,ចន្លោះពីការងារធ្វើស្រែចំការមកចិញ្ចឹមមាន់បន្ថែមដើម្បីសំរួលដល់ជីវភាពរស់នៅ ព្រមទាំងកាត់បន្ថយការចំណាយថវិកាបានមួយកំរិតទៀត ។

**តំរូវការសំខាន់ៗក្នុងការចិញ្ចឹមមាន់**

-ការរេះធ្វើផែនការចិញ្ចឹម

-ពូជ

-ទីកន្លែង និង ទ្រុង

-ចំណី និង ទឹក

-អនាម័យ និងការថែទាំ

-ការព្យាបាល និងការការពារ

-ការយល់ដឹងពីជំងឺផ្តាសាយបក្សី

-ការប្រមូលលក់ និង ការទុកពូជបន្ត



***១.ការជ្រើសរើសពូជ***

**ក.ពូជមាន់ក្នុងស្រុកៈ**

-មាន់សំពៅ

-មាន់ស្គួយ

-មាន់សំឡី

- មាន់ចៃ

-មាន់ក្រញាស់

-មាន់គក

ពូជមាន់ទាំងនេះខ្លួនតូច ធំយឺត ពងតិច តែធន់នឹងជំងឺ ។

**ខ.ពូជមាន់នាំចូលៈ**

-ភ្លីមុតរ៉ុក , ឡេហ្គន់ , រ៉ូតអាតឡិនរិត

**ការជ្រើសរើសមាន់មកចិញ្ចឹមយកសាច់**

គឺត្រូវជ្រើសយកពូជមាន់កូនកាត់ រវាងមាន់ពូជយកសាច់ ឬមាន់ពូជយកពង បង្កាត់ នឹង ពូជមាន់ក្នុងស្រុកជាពូជមាន់កណ្តួងខ្លួនធំព្រោះ ការលូតលាស់របស់វាលឿនដែលនាំអោយរយៈពេលនៃការចិញ្ចឹមប្រមាណជាងង ៣ ខែអាចលក់បាន ។

ពូជមាន់កណ្តួង (ក្នុងស្រុក)



ពូជមាន់យកសាច់ / យកពង




**ការជ្រើសរើសទីកន្លែង**



-ដីទួលមិនលិចទឹក

-ជិតប្រភពទឹក អាកាសធាតុល្អ (មាន ខ្យល់អាកាសចេញចូល)

-ឆ្ងាយពីព្រៃ មានដើមឈើបន្តិចបន្តួច

-ក្បែរផ្ទះ មានស្មៅដុះ

-ទីធ្លាទូលាយ ហ៊ុំព័ទ្ធសំណាញ់ជុំវិញ កំពស់ ៣.៥ម៉ែត្រ

**ការសង់ទ្រុងៈ**

ការសង់ទ្រុងមាន់មានពីររបៀបគឺៈ

**១.ទ្រុងចិញ្ចឹមមាន់បង្ខាំង**

ទ្រុងមាន់បង្ខាំងប្រើសំរាប់អ្នកចិញ្ចឹមដែលគ្មានទីលានគ្រប់គ្រាន់។ ទ្រុងបែបនេះអាចចិញ្ចឹមបានច្រើនក្បាល ហើយសំរាប់ចិញ្ចឹមមាន់យកពង និងមាន់យកសាច់ ។



*ទ្រុងមាន់បង្ខាំងមាន ២របៀបៈ*

-ទ្រុងមាន់ខ័ណ្ឌជាថត

-ទ្រុងចិញ្ចឹមបង្ខាំងជាហ្វូង

**២. ទ្រុងចិញ្ចឹមពាក់កណ្ដាលបង្ខាំង ពាក់កណ្ដាលសេរីៈ**

ទ្រុងបែបនេះសំរាប់ចិញ្ចឹមមាន់យកសាច់ គឺទ្រុងធ្វើឡើងដោយមានរបងព័ទ្ធជុំវិញមានសំបុក និងកន្លែងដេកត្រឹមត្រូវ ហើយសត្វអាចដើររកស៊ីដង្កូវ បន្លែ បង្ការ ដែលមានដុះនៅក្នុងទីធ្លា ។ ក្រៅពីនេះម្ចាស់សត្វត្រូវចាត់ចែងដាក់បន្ថែមចំណីស៊ីអោយបានគ្រប់គ្រាន់ ។

មេរៀនទី៣

# ការថែទាំមាន់

ជាទូទៅគេអាចចិញ្ចឹមមាន់បានគ្រប់រដូវ ។ ប៉ុន្តែរដូវដែលសមស្របបំផុតសំរាប់ចិញ្ចឹមមាន់អោយបានធំធាត់របស់ គឺនៅរដូវភ្លៀង និងដើមរដូវរំហើយ ។

***របៀបថែទាំកូនមាន់ក្រោយពេលញាស់:***

-មុនដាក់កូនមាន់ចេញពីសំបុក ត្រូវក្រាលកំទេចចំបើង ឬអាចម៍រណាជាមុនសិន ។

-ត្រូវឧស្សាហ៍ផ្លាស់កំទេចចំបើង ឬ អាចម៍រណានៅពេលវាសើម ឬមានក្លិនមិនល្អ ។

-កូនមាន់ទើបញាស់មានអាយុ ១២ម៉ោងដំបូង កុំអាលអោយចំណីស៊ី ព្រោះវានៅមានសារធាតុចិញ្ចឹមបំរុងខ្លួនវានៅឡើយ ។

-កូនមាន់អាយុ ២-៣ថ្ងៃ ត្រូវកាត់ចំពុះលើកទី ១ (កាត់ចុងចំពុះខាងលើអោយខ្លីជាងខាងក្រោម ) ដើម្បីងាយអោយសត្វចឹកចំណី ។

-កូនមាន់អាយុ ២ សប្តាហ៍ ត្រូវកាត់ចំពុះលើកទី២ ទៀត ការពារកូនមាន់ចឹកគ្នា ឬចឹកកាយចំណីចោល ។

-ត្រូវលាងស្នូកទឹក ឬ ស្នូកចំណីអោយបាន ២ដង ក្នុង ១ថ្ងៃ ។ ត្រូវប្រើទឹកក្រេស៊ីល ឬហ្វ័រម៉ុលបាញ់លើផ្ទៃក្នុងទ្រុងអោយបាន ២ ដង ក្នុង ១ ឆ្នាំ ដើម្បីរំងាប់មេរោគ ។

-ក្នុងទ្រុងកូនមាន់ត្រូវមានសីតុណ្ហភាពមួយសមស្របទៅនឹងអាយុមាន់គឺ:

| **អាយុកូនមាន់(សប្តាហ៍)** | **សីតុណ្ហភាព (អង្សាសេ)** |
|---|---|
| ០-១ | ៣៥-៣២ |
| ១-២ | ៣២-២៩ |
| ២-៣ | ២៩-២៦ |
| ៣-៤ | ២៦-២៣ |
| ៤-៥ | ២៣-២០ |

**កំណត់សំគាល់:**

-គេអាចប្រើចង្កៀងប្រេងកាត ឬ អំពូលអគ្គិសនី សំរាប់កំដៅកូនមាន់នៅកន្លែងចិញ្ចឹម ព្រោះវាត្រូវការកំដៅណាស់ ក្នុងដំណាក់កាលនោះ ។

-បើកូនមាន់ទទួលកំដៅមិនបានគ្រប់គ្រាន់ធ្វើអោយកូនមាន់ដេកផ្តុំគ្នា ។

-បើកូនមាន់ទទួលកំដៅខ្លាំងពេក ធ្វើអោយកូនមាន់ដេកបែកពីគ្នា ។

-បើកូនមាន់ទទួលកំដៅល្មម នោះកូនមាន់ដេក ឬ ដើររើសចំណីក្នុងទ្រុងស៊ី ។

**តំរូវការទឹកសំរាប់កូនមាន់:**

| ចំនួនកូនមាន់ (ក្បាល) | អាយុកូនមាន់ (សប្តាហ៍) | ចំនួនទឹកក្នុង១ថ្ងៃ |
|---|---|---|
| ១០០ | ១ | ៤ លីត្រ |
| ១០០ | ២ | ៥ លីត្រ |
| ១០០ | ៣ | ៦ លីត្រ |
| ១០០ | ៤ | ១០ លីត្រ |

**២.ការចិញ្ចឹមមាន់ជំទង់:**

មាន់ជំទង់ដែលមានអាយុពី៨សប្តាហ៍ឡើងទៅ ។អាចរក្សាទុកសំរាប់ធ្វើពូជនិងមាន់សាច់ ។ ការចិញ្ចឹមមាន់ត្រូវផ្តល់ចំណីអាហារអោយបានគ្រប់គ្រាន់ដើម្បីការលូតលាស់លឿន និងឆាប់ធំ ។

ការទំលាក់ព្រូនមាន់រៀងរាល់ ៣ខែម្តង ក៏ជាការចាំបាច់សំរាប់ការធំធាត់របស់មាន់ដែរ ។

**៣.ការចិញ្ចឹមមេមាន់ដើម្បីយកពងភ្ញាស់/កូន:**

មាន់មេចាប់ផ្តើមពងនៅអាយុ ៥ ខែឡើងទៅ ។ ការចិញ្ចឹមមេមាន់ត្រូវថែរក្សាដោយយកចិត្តទុកដាក់ គឺ ផ្តល់ចំណីអាហារអោយបានគ្រប់គ្រាន់ និងមានគុណភាពល្អ ដូចជា: ម្សៅត្រី កន្ទក់ ចុងអង្ករ ,ទឹកស្អាត.......... ។



មេរៀនទី៤ 

# របៀបក្រៀវមាន់ និង ចំណីមាន់

## ក.របៀបក្រៀវមាន់

### ១.មាន់ក្រៀវ

មាន់ក្រៀវគឺជាមាន់ឈ្មោលដែលត្រូវបានវះយកពងចេញ ដើម្បីកុំអោយមានភាពចំរើនខ្លាំងនៃភេទ ។ សិរ និងណង់របស់មាន់ក្រៀវដេក រួញ ស្លាំង មានខ្លាញ់ជាប់ តាមស្បែកពោះច្រើន ។ ចំណែកមាន់មេគេមិននិយមក្រៀវទេព្រោះ ផ្តល់ផលតិចជាងការទុកអោយពង ។

**ការក្រៀវមាន់មានពីររបៀបៈ**

-ក្រៀវពីចំហៀង ឬក្រៀវក្រោមពោះ

-ក្រៀវដោយបង្កប់អ័រម៉ូន

**ក.របៀបក្រៀវពីចំហៀងៈ**

ដំបូងលាងសំអាតសំភារៈវះកាត់ និងផ្ទៃមុខត្រូវវះ ។

*-វះពីចំហៀងនៅចន្លោះឆ្អឹងជំនី ទី ៦-៧( មុខឆ្អឹងជំនីផុត)*

-ប្រើដង្កៀបរែកមុខរបួស ហើយឆូតសាច់ក្រពឹងស្រោមពោះ ។ ពេលនោះយើងនឹងឃើញពងស្វាស ពណ៌លឿង ២ ប៉ុនគ្រាប់សណ្តែកសៀង ដល់ប៉ុនម្រាមដៃនៅជាប់នឹងសរសៃឈាម ស្រប ឆ្អឹង ខ្នង ។

-ប្រើម្រាមដៃ ឬ លូកកូនស្លាបព្រាដួសយកពងស្វាស ដែលស្ថិតនៅជាប់ នឹងជួរឆ្អឹងខ្នង ។ ចំណែក មុខរបួស នឹងជាសះស្បើយក្នុងរយៈពេល ពី ១-២សប្តាហ៍ក្រោយ ។

**ខ.របៀបក្រៀវក្រោមពោះ**

ដំបូងលាងសំអាតសំភារៈវះកាត់ និងផ្ទៃមុខត្រូវវះ

-កន្លែងដែលត្រូវវះគឺ ចំងាយពីរន្ធគូទអាក់ មកខាងក្រោមពោះ ប្រវែង ៤-៥ស.ម ។

-មុខរបួសដែលត្រូវវះប្រវែង ៣-៤ស.ម សំរាប់លូកម្រាមដៃពីរចូល ។

-បន្ទាប់ពីបើកមុខរបួសហើយ ប្រើម្រាមចង្អុលដៃ និង ម្រាមកណ្តាលគាបផ្តាច់យកពងចេញមកក្រៅ ។ ផ្តាច់យក ពងម្ខាងទៀត ដោយធ្វើរបៀបដូចគ្នា ។

-បន្ទាប់មកសំអាតមុខរបួស ហើយដេរដោយប្រើអំបោះឆៅ ២-៣ថ្នេរប៉ុណ្ណោះ ។

-ជាចុងក្រោយប្រើថ្នាំតាំងទៃអ៊ីយ៉ូត ជូតសំអាតមុខរបួស ឬយកធ្យូងបាតខ្ទះលាបលើមុខរបួស ។

**គ.របៀបក្រៀវដោយអ័រម៉ូន**

ការក្រៀវមាន់បែបនេះ អាចធ្វើអោយមាន់ធំធាត់លឿនជាងការក្រៀវតាមរបៀបចំហៀង ។

វិធីក្រៀវដោយចាក់អ័រម៉ូននេះ គេប្រើអ័រម៉ូនភេទមេទំហំប៉ុនថ្នាំដែកកេះ ទំងន់ ១៥មីលីក្រាម ដោយបញ្ចុះវាទៅ ក្នុងគល់សិរផ្នែកខាងក្រោយ ។ វិធីនេះអាចអនុវត្តលើមាន់អាយុ ១៦សប្តាហ៍ ។ ក្រោយពីក្រៀវរួច ៥ខែ មាន់ក្រៀវអាចហួបបាន ។

**កុំកាន់អ័រម៉ូនដោយដៃទទេ ព្រោះវាអាចជ្រាបចូលតាមស្បែកធ្វើអោយយើងគ្មានកូន ។**

**ឃ.ចំណីមាន់ក្រៀវ**

ផ្តល់ចំណីដែលមានជាតិប្រូតេអ៊ីន ១៥-១៦ភាគរយ។ ផ្តល់គ្រាប់រុក្ខជាតិ ដូចជា ស្រូវ ពោតម៉ត់។ ជាមួយគ្នានេះដែរ **ចំណីត្រូវផ្សំលាយដោយរូបធាតុដើមមួយចំនួនដូចជា**

| | |
|---|---|
| -ពោត លាយចុង អង្ករ | ១៥ ភាគរយ |
| -កន្ទក់ម៉ត់លេខ ២ | ៥០ភាគរយ |
| -កាកសណ្តែកសៀង សណ្តែកដី | ៦ភាគរយ |
| -ម្សៅត្រី ស្លឹកកន្ធំថេត | ៣ ភាគរយ |
| -សំបកខ្យងបុក | ១.៥ ភាគរយ |




**ខ.ចំណីមាន់**

**សារៈប្រយោជន៍**

ចំណីមានសារៈសំខាន់ណាស់សំរាប់ការលូតលាស់របស់មាន់ ។ ចំណីផ្សំឡើងពីសារធាតុជាច្រើនដែលក្នុងនោះសារធាតុដែលសំខាន់ចាំបាច់មានៈ

**-ប្រូតេអ៊ីន**

ជំនួយអោយរាងកាយធំធាត់លឿន ដោយវាដើរតួនាទីយ៉ាងសំខាន់ក្នុងការបង្កើតជាលិកាថ្មី របស់បក្សី សំរាប់ការលូតលាស់ និងការបន្តពូជ ។

ប្រូតេអ៊ីនមាននៅក្នុងៈ សណ្តែកសៀង កាកសណ្តែកដី កាកសណ្តែកបាយ .................. សត្វល្អិតផ្សេងៗ ក៏ ផ្តល់ជាតិប្រូតេអ៊ីនដែរ ដូចជាកណ្តៀរ ជន្លេន ចង្រិត ។ល។

**-ថាមពល**

សំរាប់ផ្តល់អោយរាងកាយមានសកម្មភាព និងលូតលាស់ ។ ចំណីដែលសំបូរថាមពលមានៈ កន្ទក់ ចុងអង្ករ ពោត កាកដំឡូងឈើ ស្ករ ។

**-ជាតិខនិជ ឬ រ៉ែ**

សំរាប់ជួយអោយឆ្អឹងលូតលាស់ និងសំបកស៊ុតរឹង ។ ចំណីដែលសំបូរជាតិរ៉ែមានៈ ម្សៅឆ្អឹង សំបកខ្យង ខ្ចៅ សំបកគ្រុំ សំបកលៀស ។

**-ជីវជាតិ**

សំរាប់បង្កើនភាពរឹងមាំ ប្រឆាំងនឹងមេរោគ ។ ចំណីដែលសំបូរជីវជាតិមានៈ បន្លែ ស្មៅ រុក្ខជាតិបៃតង ( ស្លឹកកន្ធំថេត ស្លឹកអង្គារដី ស្លឹកដំឡូង ស្លឹកស្ពៃ ត្រកួន ) ។ល។

**-អំបិល**

ជួយបន្ថែមភាពឆ្ងាញ់ទៅលើចំណី ធ្វើឱ្យសត្វស៊ីចំណីបានច្រើន ។ ក្នុងការផ្សំចំណី គឺក្នុងចំណី ៥០ គួរបន្ថែមអំបិល ១ ។

**គំរូរូបមន្តចំណីមាន់ៈ**

| **ប្រភេទចំណីឆៅ** | **កូនមាន់ (គ.ក្រ)** | **មាន់ពង (គ.ក្រ)** | **មាន់សាច់(គ.ក្រ)** |
|---|---|---|---|
| កន្ទក់ម៉ត់ | ១០ | ២៩.៥ | ៣០.៥ |
| ចុងអង្ករ | ១០.៨ | ៥ | ១០ |
| ពោតក្រហម | ៤៣ | ៣០ | ៣០ |
| កាកសណ្តែកសៀង | ១២ | ១០ | ១០ |
| ម្សៅត្រី | ២០ | ២០ | ១៥ |
| សំបកខ្យង . ខ្ចៅ | ៤ | ៥ | ៤ |
| អំបិល | ០.២ | ០.៥ | ០.៥ |

**ករណីក្រខ្សត់ចំណី**

**ចំពោះតំបន់ខ្លះដែលប្រជាជនខ្វះទុន សំរាប់ទិញចំណីផ្សំខាងលើ អាចរកចំណីតាម ធម្មជាតិដែលអាចមាន នៅមូលដ្ឋានគឺៈ**

១-ដើមដំឡូងជ្វា ត្រាវ ដំឡូងមី ហាន់វាអោយល្អិត ហាលអោយស្ងួត ទុកបាចឱ្យសត្វស៊ី

២-ស្លឹកកន្ធំថេត រុក្ខជាតិ និងកាកសំណល់បន្លែផ្សេងៗ (កិនអោយម៉ត់ )

៣-កន្ទក់អង្ករ កន្ទក់ស្រូវ ពោតកិនអោយម៉ត់

៤-សត្វល្អិតតូចដង្កូវ កណ្តៀរ ជន្លេន កណ្តូប ។ល។

៥-ទឹកស្អាត (ទឹកអណ្តូង ត្រពាំង បឹង..............



**រូបមន្តចំណីមាន់ងាយស្រួល**

-គ្រាប់ពោតក្រហម កិន ឬចុងអង្ករ ៤ កំប៉ុង

-កន្ទក់ ១ កំប៉ុង កន្លះ

-ម្សៅត្រី ឬសំបកខ្យង ១ កំប៉ុង

-ម្សៅដំឡូងស្ងួត ១កំប៉ុង កន្លះ

-ស្លឹកកន្ធំថេតស្ងួត កន្លះកំប៉ុង

-អំបិល ១ ស្លាបព្រាបាយ

-កំបោរ កសិកម្ម ឬ ម្សៅសំបកគ្រុំ ឬលៀស ១ទូកដៃ




**របៀបផ្តល់ទឹក និងចំណី**

-ចំណីមាន់ត្រូវផ្តល់ ៣ដង ក្នុងមួយថ្ងៃ ( ករណីចិញ្ចឹមលែងផ្តល់ឱ្យតែ២ដង ក្នុងមួយថ្ងៃ គឺពេលព្រឹកនិងពេលល្ងាច ) ដោយមានស្នូកចំណីឱ្យបានត្រឹមត្រូវចៀសវាង ការខ្ជះខ្ជាយចំណីឥតប្រយោជន៍ ។

-ការផ្តល់ទឹក គឺទឹកស្អាត ដោយប្រើចានជ័រ ចានដែកធម្មតា ឈើធ្វើជាស្នូកទឹក ដែកស័ង្កសី ឬក៏អាចជាបំពង់ទិបស្វ័យប្រវត្តិ ឱ្យមាន់ចឹក ។

**តម្រូវការទឹករបស់សត្វមាន់**

| ចំនួនមាន់ | អាយុ | បរិមាណទឹក | ផ្សេង |
|---|---|---|---|
| ១០០ | ១សប្តាហ៍ | ៤លីត្រ | |
| ១០០ | ២សប្តាហ៍ | ៥លីត្រ | |
| ១០០ | ៣សប្តាហ៍ | ៦លីត្រ | |
| ១០០ | ៤សប្តាហ៍ | ១០លីត្រ | |

# មេរៀនទី៥ លក្ខណៈទូទៅនៃវ៉ាក់សាំងការពារជំងឺមាន់

**១.លក្ខណៈវ៉ាក់សាំង**

-វ៉ាក់សាំងគឺជាប្រភេទថ្នាំម្យ៉ាងដែលមានលក្ខណៈខុសពីប្រភេទថ្នាំព្យាបាល ។គេផលិតថ្នាំវ៉ាក់សាំងពីបាក់តេរី ឬវីរុស (រស់ ) ព្រមទាំងគ្រឿងបន្សំផ្សេងទៀតទៅ តាមប្រភេទវ៉ាក់សាំងនីមួយៗ ។

-វ៉ាក់សាំងគឺជាថ្នាំសំរាប់ការពារ ជំងឺឆ្លងរាតត្បាត វាមិនមែនជាថ្នាំព្យាបាលទេ ។

-ថ្នាំការពារប្រឆាំង និងជំងឺមួយ ធ្វើឡើងដោយមេរោគនៃជំងឺនោះ ដែលត្រូវបានគេធ្វើអោយខ្សោយ

-ចាក់ថ្នាំការពារវាមិនបណ្តាលអោយសត្វកើតជំងឺនោះទេ និងធ្វើអោយខ្លួនសត្វមានលទ្ធភាពទប់ទល់មេរោគនោះបាន ។

-វ៉ាក់សាំងមួយប្រភេទ គឺ ការពារបានជំងឺតែមួយមុខប៉ុណ្ណោះ ។

**ឧទាហរណ៍:** វ៉ាក់សាំងការពារជំងឺអាសន្នរោគ សំរាប់ការពារជំងឺអាសន្នរោគ មួយមុខគត់ វាមិនមែនសំរាប់ការពារជំងឺអុតបក្សីមួយទៀតឡើយ ។

-ត្រូវចាក់វ៉ាក់សាំងអោយសត្វណាដែលមានសុខភាពល្អ ។

**២.ប្រភេទផ្សេងៗ នៃវ៉ាក់សាំង:**

**ក.វ៉ាក់សាំងញូវកាសះ** មាន៣ប្រភេទ

**-វ៉ាក់សាំងញូវកាសអែហ្វ** សំរាប់បន្តក់ច្រមុះ ឬ ភ្នែកទាំងសងខាងពី ១-២ តំណក់ លើមាន់មានអាយុ ៣ថ្ងៃ-២ខែ និងមានភាពស៊ាំនឹងជំងឺរយៈពេល ២១ថ្ងៃ សំរាប់ការពារជំងឺញូកាសអែហ្វ ។

**-វ៉ាក់សាំងញូវកាសអឹម** សំរាប់ចាក់សាច់ដុំ ឬសើស្បែកក្នុងកំរិត ០.៥ ម.ល លើមាន់មានអាយុពី ៨អាទិត្យឡើង និងមានភាពស៊ាំ និងជំងឺរយៈពេល ៣ខែ សំរាប់ការពារជំងឺញូកាសអឹម ។

**-វ៉ាក់សាំងញូវកាសឡាសូតា** សំរាប់លាយទឹកអោយកូនមាន់ផឹក ១ខែម្តង សំរាប់ការពារ - ជំងឺញូកាស ឡាសូតា ។

**ខ.វ៉ាក់សាំងអុតបក្សី**

សំរាប់ចាក់បន្ទះស្លេីងស្លាបរង លើមាន់ អាយុ ៧ថ្ងៃឡើង ក្នុងកំរិតថ្នាំ ១ ដងនិងមានភាពស៊ាំជំងឺមួយឆ្នាំ ។

**គ.វ៉ាក់សាំងអាសន្នរោគ**

ចាក់សាច់ដុំលើមាន់អាយុពី ១០អាទិត្យក្នុងកំរិត ១ ម.ល/ចាក់ពីរដងក្នុង ១ឆ្នាំ និងមានភាពស៊ាំជំងឺ ៦ ខែ សំរាប់ការពារជំងឺអាសន្នរោគ ។

**៣.ការថែរក្សាទុកដាក់វ៉ាក់សាំង**

-ត្រូវរក្សាថ្នាំការពារនៅកន្លែងត្រជាក់ជានិច្ច (ក្នុងធុងទឹកកក ) ។

-ត្រូវយកស្បោងកៅស៊ូស្រោបដបថ្នាំ និងចងមាត់អោយជិតមុនទុកក្នុងធុងទឹកកក ការពារកុំអោយរបកផ្លាកថ្នាំ ។

-ត្រូវទុកថ្នាំការពារអោយឆ្ងាយពីដៃក្មេង ។

**៤.សំភារៈប្រើប្រាស់វ៉ាក់សាំងដល់មាន់**

-ម្ជុល, សឺរ៉ាង, ដែកចាក់ស្លាប , កន្ត្រៃ , ដង្កៀបចាប់ម្ជុល

**៥.បច្ចេកទេសសំរាប់ផ្តល់វ៉ាក់សាំងដល់មាន់**

**ក.ការចាក់ថ្នាំក្រោមស្បែកនិងចូលក្នុងសាច់ដុំ**

-វិធីនេះទាមទារការរំងាប់មេរោគលើឧបករណ៍ប្រើប្រាស់ជាមុន មុនយកវាទៅប្រើប្រាស់

-នៅពេលចាក់ថ្នាំជារឿយៗ ត្រូវទាញស៊ីរាំងមកក្រោយដើម្បីពិនិត្យមើលថាការចាក់ថ្នាំនេះមិនចូលសរសៃឈាមទេ ។

**ខ.ផ្លូវបញ្ចូលថ្នាំតាមភ្នែក**

-ប្រើដោយការដាក់ថ្នាំដែលជាក្រែម ឬ ប៉ូម៉ាត ឬ រាវ ដើម្បីព្យាបាលភ្នែកដែលមានជំងឺឆ្លង ។ វ៉ាក់សាំង ញូវកាសអែហ្វ អាចប្រើតាមវិធីនេះទៅលើមាន់ចាស់ថ្ងៃ ។ យើងបន្តក់វ៉ាក់សាំង ១ ឬ ២តំណក់ដាក់ក្នុងភ្នែក ។ វាមិនបណ្តាលអោយឈឺចាប់អ្វីទេ ។

**គ.របៀបចាក់នៅលើស្លាប**

-អាចប្រើលើបក្សីគ្រប់ទាំងអស់ ។ វ៉ាក់សាំងការពារជំងឺអុត និង ញូវកាសអឹម អាចប្រើតាមវិធីនេះ ព្រោះវាជាវិធីយ៉ាងរហ័សហើយងាយស្រួល ។ យើងប្រើម្ជុលពិសេសជ្រលក់ចូលទៅក្នុងវ៉ាក់សាំងហើយ ចុចម្ជុលនេះទៅលើស្បែកស្លាប ។

**កំណត់ចំណាំ**

-វ៉ាក់សាំងនីមួយៗ មានប្រសិទ្ធិភាពជាកំណត់ ដោយយោងទៅតាមប្រភេទវ៉ាក់សាំងខ្លះមានប្រសិទ្ធិភាពរយះពេល ៦ខែ ខ្លះទៀតមានដល់ ១ឆ្នាំ ។

-ជាការល្អត្រូវចាក់វ៉ាក់សាំង ១ ឆ្នាំអោយបាន ២ដង រាល់គ្រប់មុខជំងឺ ។

-ត្រូវដុត ឬកប់ចោលដបថ្នាំដែលប្រើរួច ។

# វិធីសាស្ត្រផ្តល់ថ្នាំការពារដល់បក្សី ( មាន់ )



# ជំងឺមាន់ និង វិធានការការពារ - ព្យាបាល

# ជំងឺញូវកាស

ជំងឺនេះឆ្លងរាលដាលខ្លាំងក្លាបំផុត អាចបណ្តាលអោយសត្វស្លាប់ទាំងស្រុង យើងសង្កេតឃើញមាន់មួយចំនួនក្នុងហ្វូង ចុះខ្សោយ សំកុក ធ្លាក់ស្លាប ភ្នែកព្រឹម ស៊ីតិច ឬអត់ស៊ី ផឹកទឹកច្រើន ប្រសិនបើយើងវាស់កំដៅឡើងដល់ ៤២-៤៣ អង្សាសេ ជាទូទៅជំងឺនេះច្រើនកើតនៅក្នុងខែ មេសា និង តុលា (ពីខែចែត្រ-អស្សុជ ) ។ មាន់ឈ្មោលឈប់រងាវ មេមាន់ថយពងលាមក ក៏មានដុំស ក្លិនឆេះឆួល ។

**១.មូលហេតុ**

ជំងឺញូវកាសគឺជាជំងឺមួយដែលឆ្លងរាតត្បាត យ៉ាងសាហាវបំផុតដែលបង្កឡើងដោយវីរុស ។

**២.រោគសញ្ញា**

-ពិបាកដកដង្ហើម ហាមាត់ដូចស្វាប ហៀរទឹកសំបោរ

-រាគលាមកខៀវ ហើយប្រែបន្តិច ទៅជា ស

-មានលាយឈាមក្លិន ឆ្អាប មាត់ហៀរ ទឹករំអិល ក្នុងគែរ មានទឹកពេញ

-ញាក់ ញ័រកន្ត្រាក់ខ្លួន កាច់ក កូនមាន់ និង មាន់ជំទង់ងាប់ ហើយជំងឺនេះកើតច្រើនជាងមាន់ធំ



**៣.ការព្យាបាល**

-ជំងឺនេះ គ្មានថ្នាំព្យាបាលទេ

**៤.ការការពារ**

-ត្រូវធ្វើអនាម័យអោយបានស្អាតល្អ (ទ្រុង,ស្នូកទឹក,ចំណី )

-ត្រូវបំបែកសត្វដែលឈឺ ឬ សង្ស័យឈឺ ចេញពីសត្វជា អោយបានឆ្ងាយ ។

ត្រូវដុត ឬ កប់សាកសពមាន់ឈឺចោល ( ហាមសំលាប់សត្វឈឺធ្វើជាអាហារ ) ។

# ជំងឺអុតបក្សី

ជំងឺអុតបក្សីច្រើនកើតនៅរដូវស្ងួត និងរដូវសើមគឺ: ពីខែតុលា ដល់ខែ មិនា រឺ ពីខែអស្សុជ ដល់ ខែ ផល្គុន

**១.មូលហេតុ:** បណ្តាលមកពីវីរុសម្យ៉ាងដែលចូលចិត្តរស់នៅលើខ្លួនសត្វ និងលើដី ។

**២.ការឆ្លងរាលដាល**

-មូស , ចៃ , រុយ

- ចំណីអាហារ

-សំភារៈប្រើប្រាស់ផ្សេងៈ ស្នូកទឹក ឬ ចំណី

-វីរុសជ្រៀតចូលតាមមាត់ និងស្បែកមានរបួស

**៣.រោគសញ្ញាៈ គេចែកជាបីសណ្ឋានគឺៈ**

**-សណ្ឋានសើស្បែកៈ** ដុំពកមានពណ៌កូលាប ឬ លឿងហើយប្រែជាក្រម៉រ នៅលើកន្លែង អត់រោម ដូចជាសិរ ខ្នង់ច្រមុះ គែមចំពុះ ជុំវិញភ្នែកត្រចៀក ជើង បើកើតលើភ្នែក ធ្វើឱ្យភ្នែក ខ្វាក់កើតលើចំពុះ ពិបាកស៊ី ផឹក កើតលើច្រមុះ ពិបាកដកដង្ហើម ។

**-សណ្ឋានអុតក្នុងមាត់ និង ក្នុងបំពង់កៈ** ក្នុងមាត់ និង ក្នុងបំពង់ក មាន រលាក កកឈាម ។ ចំណុចពណ៌សលឿង ចំណុច នេះរាលពកជាដុំ ឬជាបន្ទះ ច្បាមជាប់នៅក្នុងមាត់ ។ បន្ទះបិទនោះបិទជាប់បំពង់កធ្វើឱ្យស្ទះដង្ហើម ងាប់ ។

**-សណ្ឋានអុតនៅភ្នែក និងច្រមុះ** មាន់ឈឺរលាកភ្នែកមានពពីកភ្នែក ត្របកភ្នែក និង ត្របកភ្នែកជាប់គ្នា ច្រមុះ រលាក ហៀរទឹក ពេលទឹកច្រមុះស្ងួតក្រៀម បិទរន្ធច្រមុះ នាំឱ្យពិបាកដកដង្ហើម ។

**៤.ការព្យាបាលៈ** គ្មានថ្នាំលេប/បញ្ចូក ព្យាបាលទេ

**-បកក្រម៉រចេញ លាងដោយអាល់កុល រួចលាបថ្នាំ**

***បេតាឌីនឬថ្នាំពណ៌ស្វាយ***

***ប៊្លីដឺមេទីឡែន ឬថ្នាំខៀវ***

***តាំងទៀឌីយ៉ូត***

**៥.ការការពារ**

-អនាម័យ

-ការចាក់ថ្នាំការពារៈ អង់ទីវ៉ារីយូលិក (ចាក់គ្រប់អាយុ)

-បំបែកមាន់ឈឺចេញ ពីមាន់ជា

-ដុត ឬកប់សាកសពមាន់ដែលមានជំងឺចោល



# ជំងឺអាសន្នរោគមាន់

ជំងឺនេះច្រើនកើតចំពោះមាន់ធំ (មាន់ពង)ដែលចិញ្ចឹមក្នុងលក្ខណៈកខ្វក់ ឬការចិញ្ចឹមដោយពុំបានប្រើថ្នាំការពារ ។ ជាប្រភេទជំងឺឆ្លងសាហាវ និងកើតនៅក្រោយពេលភ្លៀងធ្លាក់ និង ដើមរដូវវស្សា ។

**១.មូលហេតុ** ជំងឺនេះបណ្តាលមកពីបាក់តេរី ។

**២.រោគសញ្ញា** ចែកចេញជាពីរសណ្ឋាន

**ក.សណ្ឋានស្រួចស្រាវបំផុត**

-មិនស៊ីចំណីសោះ

-សិរ និងណង់ពណ៌ស្វាយ

-ទឹកសំបោរខាប់ ហៀរតាមច្រមុះ ,មាត់

-អាចស្លាប់ក្នុងរយៈពេល ២៤-៤៨ម៉ោង

**ខ.សណ្ឋានស្រួចស្រាវ**



-សំកុកមិនស៊ីចំណី ២-៣ថ្ងៃ

-សីតុណ្ហភាពឡើងខ្លាំង៤០អង្សារ

-ដកដង្ហើមញាប់

-សិរពណ៌ស្វាយរួចឡើងជាំខ្មៅ

-ទឹកសំបោរមានលាយឈាម

-រាគមានលាយសំបោរ ឬ លាយឈាម

**៣.ការព្យាបាល**

គួរព្យាបាលសត្វដែលនៅជាមួយគ្នាទាំងឈឺ ទាំងជា

-សត្វជា ប្រើតេត្រាស៊ីគ្លីនគ្រាប់ ២៥០ម.ក្រ ចំនួន៤គ្រាប់ក្នុង១ថ្ងៃសំរាប់មាន៥ក្បាល ក្នុងរយៈពេល ៣-៥ថ្ងៃ

-សត្វឈឺ ប្រើអុកស៊ីតេត្រាស៊ីគ្លីន ១០% ចាក់សាច់ដុំ ០,២-០,៥ម.ក្រ/ក្បាល ព្យាបាល ៣-៥ថ្ងៃ

**៤.ការការពារ**

-បង្ខាំងមាន់ទើបនឹងបញ្ចូលថ្មីដាក់ដោយឡែកចំនួន ១៥ថ្ងៃ, បំបែកបក្សីជា ពីបក្សីឈឺ

-មានវិធានការអនាម័យ និងចាក់វ៉ាក់សាំងការពារពេលមាន់អាយុ ១០អាទិត្យ

# ជំងឺរាគអាចម៍ស

ជម្ងឺរាគសជាជម្ងឺឆ្លង ច្រើនកើតនៅលើមាន់គ្រប់វ័យ ។ ចំណុចពិសេសនៃជម្ងឺនេះ គឺរាគលាមកស ចុះទម្ងន់អត្រាងាប់ ៤០-៥០ ភាគរយ ។



**១-មូលហេតុ** បង្កឡើងដោយបាក់តេរី

**២-រោគសញ្ញា**

- មាន់ដេកផ្ដុំគ្នា នៅកន្លែងដែលមានកំដៅ
- មាន់សំកុក, ភ្នែកបិទ, មិនស៊ីចំណី
- លាមករាគពណ៌ស
- សិរឡើងពណ៌ស្វាយ, ដំណើរទ្រេតទ្រោត
- ហៀរទឹករំអិលតាមមាត់
- សត្វចុះស្គម, អាចស្លាប់ក្នុងរយៈពេល ៥ -១០ថ្ងៃ
- ស្លាបធ្លាក់ចុះក្រោម



**៣- ការព្យាបាល**

- ប្រើថ្នាំភូរ៉ាសូលីដូន ព្យាបាលរយៈពេល ៥ ថ្ងៃ

**លាយចំណី** កំរិតថ្នាំ ២-៣ ក្រាមក្នុងចំណី ១០ គីឡូក្រាម

**លាយទឹក** កំរិតថ្នាំ ២-៣ ក្រាម ក្នុងចំណុះ ៥ លីត្រ

**៤- ការការពារ**



- អនាម័យទ្រុង និងទីធ្លាអោយបានស្អាតជាប់ជានិច្ច
- ដុតសាកសពមាន់ឈឺ និងកាកសំណល់វាចោល
- ត្រូវកំទេចចោលនូវមេពូជណាដែលមានដក់ជម្ងឺក្នុងខ្លួន

**ចំណាំ**

- ជម្ងឺនេះអាចឆ្លងពីមេទៅកូនតាមរយៈពង

-ចំណីអាហារ, ទឹក និងបរិយាកាសជុំវិញដែលមិនស្អាត ។

# ជំងឺផ្តាសាយបក្សី

ជំងឺផ្តាសាយបក្សីជាជំងឺឆ្លងដែលបង្កដោយវីរុសនិងបង្កជាជំងឺលើសត្វស្លាបគ្រប់ប្រភេទរួមទាំងមាន់មាន់បារាំងមាន់ទោ ក្រួច ទា ក្ងាន និង បក្សីផ្សេងទៀត ហើយអាចឆ្លងទៅជ្រូក និងសត្វដទៃទៀតដូចជា ឆ្មា ខ្លា ជាដើម ជំងឺនេះមិនត្រឹមតែខាតបង់យ៉ាងធ្ងន់ធ្ងរដល់សេដ្ឋកិច្ចគ្រួសារ និង សេដ្ឋកិច្ចជាតិប៉ុណ្ណោះទេ ហើយថែមទាំងគ្រោះថ្នាក់ដល់ជីវិតមនុស្សទៀតផង ។

**ក.រោគសញ្ញា**

សភាពនៃជំងឺផ្តាសាយបក្សីមានលំដាប់ស្រាលរហូតដល់ធ្ងន់ធ្ងរដែលអាចបណ្តាលឱ្យងាប់ ។ ប្រភេទ វីរុសបណ្តាលឱ្យបក្សីងាប់យ៉ាងឆាប់រហ័ស ជាពិសេសនៅលើកូនសត្វ ដោយមិនបញ្ចេញជារោគសញ្ញាអ្វីឡើយ ។ រោគសញ្ញាមានលក្ខណៈខុសគ្នាជាខ្លាំងអាស្រ័យលើកត្តាជាច្រើនដូចជាៈ អាយុ ប្រភេទសត្វ ការអនុវត្តន៍ចិញ្ចឹម និងប្រភេទវីរុសបង្កជំងឺ ។ បន្ទាប់ពីទទួលការចំលងនិងបង្ហាញរោគសញ្ញាដំបូង នៃជំងឺសត្វអាចងាប់ក្នុងរយៈពេលពី១-១២ថ្ងៃ។

**រោគសញ្ញាសំខាន់ នៃជំងឺផ្តាសាយបក្សីមាន**

-ការកើនឡើងនៃអត្រាសត្វឈឺ និងសត្វស្លាប់ខ្ពស់

-ហៀរសំបោរ ពិបាកដកដង្ហើម ហូរទឹកភ្នែកជួនកាលហូរឈាមតាមច្រមុះ ។

-ហើមក្បាល ត្របកភ្នែក សិរ ណង់ និង ជើង

-សិររ ណង់ ជើង ប្រែទៅជាពណ៌ស្វាយ

-សត្វសំកុក បាត់ថាមពល មិនស៊ីចំណីនិងមិនផឹកទឹក

-ចំពោះមាន់ពងការផ្តល់ស៊ុតថយចុះឬបញ្ឈប់សំបកស៊ុត

-មានអាការៈប្រកាច់មុនពេលងាប់រោមបះស្នាមជាំឈា

-រាគរុះ ចាប់ផ្តើមពីពណ៌បៃតងខ្ចី រហូតដល់ពណ៌ស

-សត្វងាប់ភ្លាម ដោយគ្មានរោគសញ្ញា ក្នុងករណីខ្លះ



ស្នាមជាំឈាមខ្មៅនៅលើស្រទាប់ភ្នាសនៃសរីរាង្គក្នុង

**ខ.ការព្យាបាល**

ពុំមានឱសថបសុពេទ្យណាមានប្រសិទ្ធភាពក្នុងការព្យាបាលជំងឺផ្តាសាយបក្សីទេ ។

**គ.វិធានការជីវសុវត្ថិភាពនៃការចិញ្ចឹមបក្សី**

-ត្រូវចិញ្ចឹមបក្សីដោយដាក់នៅក្នុងទ្រុង ឬរបងជុំ

-ជៀសវាងការចិញ្ចឹមសត្វលែងឱ្យដើរស៊ីសេរី

-ការពារការប៉ះពាល់ជាមួយសត្វព្រៃ និងសត្វបក្សីទឹក

-ត្រូវប្រើប្រាស់ចំណី និងទឹកដែលគ្មានមេរោគ

-ត្រូវចិញ្ចឹមមាន់ ទា និងសត្វផ្សេង ទៀតដាក់ដោយឡែកពីគ្នា នៅក្នុងទ្រុង ឬ របងនិងផ្តល់ចំណីជាប្រចាំ

-ជៀសវាងដាក់បក្សីដែលចិញ្ចឹមមុន និង បក្សីដែលទើបនាំចូលមកថ្មីនៅជាមួយគ្នា (បង្ខាំងបក្សីថ្មីរយៈពេល ១៤ថ្ងៃ) ។

-អនាម័យសំលៀកបំពាក់របស់អ្នកបំរើការនៅកន្លែងចិញ្ចឹមសត្វ និងអនុញ្ញាតិតែអ្នកបំរើការឱ្យចូលក្នុងកសិដ្ឋាន ។

-មិនអនុញ្ញាតិឱ្យអ្នកដទៃចេញចូល ឬ ការធ្វើទស្សនៈកិច្ចដោយសេរីនៅកន្លែងចិញ្ចឹមសត្វឡើយ

-ធ្វើអនាម័យកន្លែងចិញ្ចឹមប្រចាំៈ សំអាត និង រំងាប់មេរោគនៅកន្លែងចិញ្ចឹមសត្វបរិវេណជុំវិញកន្លែងចិញ្ចឹមសត្វសម្ភារៈប្រើប្រាស់ និង មធ្យោបាយដឹកជញ្ជូនចេញ-ចូលកសិដ្ឋាន ។

**ឃ.ការការពារ**

-សត្វស្លាបដែលទទួលការចំលងត្រូវសំលាប់ និងកប់ចោលតាមវិធានបសុពេទ្យ

-ចំណីសត្វ ឧបករណ៍ និងលាមកសត្វដែលប្រឡាក់ប្រឡូសត្រូវបំផ្លាញចោល ឬធ្វើការរំងាប់មេរោគ

-ពង្រឹងការត្រួតពិនិត្យចលនាសត្វ នៅក្នុងតំបន់ដែលកើតជំងឺ

-សំអាតរាល់ឧបករណ៍ យានយន្តមុន និងចូលទៅកសិដ្ឋាន

-ទុកសត្វដែលមិនទាន់លក់ ចេញពីសត្វដែលនាំចូលថ្មី

-កុំបញ្ជូនសត្វដែលនៅសល់ពីការលក់ទៅកសិដ្ឋានវិញ